ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈយោគយល់

រវាង

**លេខាធិការដ្ឋាន គ.ជ.អ.ប**

ជាមួយនិង

**អង្គការ ឃែរអន្តរជាតិប្រចាំកម្ពុជា**

ស្តីពី

# ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# អនុស្សរណៈយោគយល់
# រវាង
# លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)
# និង
# អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា
# ស្តីពី
# ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## ប្រការ១៖ គណនេយ្យភាពសង្គម

ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦រហូតដល់២០១៨បានរៀបចំឡើងដោយមានកិច្ចសហការយ៉ាងជិតស្និតរវាងលេខាធិការដ្ឋានគ.ជ.អ.ប និងបណ្តា អង្គការសង្គមស៊ីវិលពាក់ព័ន្ធ ក្រោមក្របខ័ណ្ឌកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ។ការងារគណនេយ្យភាពសង្គមគឺជាផ្នែកមួយដ៏សំខាន់នៃអភិបាលកិច្ច និងជាដំណើរការនៃ កាចូលរួមប្រកបដោយការស្តាបនារវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការធ្វើសេចក្តីសម្រេច ចិត្តជាសាធារណៈ និងអនុវត្តសកម្មភាពនានា។ សកម្មភាពទាំងនោះរួមបញ្ចូលនូវសកម្មភាពដែល ប្រជាពលរដ្ឋ និងតំណាងប្រជាពលរដ្ឋ អាចធ្វើការផ្តល់យោបល់ត្រឡប់សម្រាប់ឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន និង អាចចូលរួមតាមដានត្រួតពិនិត្យ អំពីការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា មន្ត្រី និងអ្នកផ្តល់សេវាតាមរយៈ សេវារដ្ឋបាលឃុំ សេវាអប់រំ (សាលាបឋមសិក្សា) និងសេវាសុខាភិបាល (មណ្ឌលសុខភាព)។

## ប្រការ២៖ គោលបំណងនៃអនុស្សរណៈយោគយល់

អនុស្សរណៈយោគយល់នេះមានគោលបំណងកំណត់អំពីការទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការរបស់ភាគីពីរគឺ លេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការឃែរអន្តរជាតិប្រចាំកម្ពុជា សម្រាប់ការអនុវត្តសកម្មភាព ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ផ.អ.គ.ស) នៅ ក្នុងតំបន់គោលដៅដូចមានក្នុងឧបសម្ព័នទី១។ អនុស្សរណៈយោគយល់នេះមានសុពលភាពរយៈពេល៣៤ខែ ចាប់ពីឆ្នាំ២០១៦ ដល់២០១៨ និងមានគោលបំណងអនុវត្តតាមផែនការសកម្មភាពគណនេយ្យភាពសង្គមដែល នឹង ធ្វើបច្ចុប្បន្នភាពតំបន់គោលដៅអនុវត្តមួយឆ្នាំម្តង ដោយពង្រីកចំនួនតាមការព្រមព្រៀង។ ភាគីទាំងពីរនឹង ខិតខំប្រឹងប្រែងស្វែងរកការគាំទ្រថវិកាដើម្បីអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងតំបន់គោល ដៅដែលបានគ្រោងក្នុងឧបសម្ព័ន្ធទី១.ខ។

## ប្រការ៣៖ ការទទួលខុសត្រូវរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋានគ.ជ.អ.ប.ព្រមព្រៀងដូចខាងក្រោម៖

ក.ផ្តល់ការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតំបន់គោលដៅស្តីពីខ្លឹមសារនៃអនុស្សារណៈយោគយល់នេះ។

ខ. ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រីជំនាញសុខាភិបាល និងមន្ត្រីជំនាញ វិស័យអប់រំនៅក្នុងតំបន់គោលដៅទាក់ទងនឹងទស្សនៈទាន ឧបករណ៍ ដំណើរការនៃការអនុវត្តផែនការ សកម្មភាពគណនេយ្យភាពសង្គម ពិសេសគោលការណ៍អភិបាលកិច្ច និងខ្សែគណនេយ្យភាព ព្រមទាំងតួនាទី ភារកិច្ចរបស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិអង្គការមិនមែនរដ្ឋាភិបាលដែលចុះកិច្ចសន្យាអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម និងអង្គការសង្គមស៊ីវិល(CSO) ដែលបានទទួលកិច្ចសន្យាពីអង្គការមិនមែនរដ្ឋាភិបាល ក្នុងការលើកកម្ពស់គោលការណ៍ខាងលើនិងគាំទ្រសម្របសម្រួលការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅ។

គ.គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋនៅតំបន់គោលដៅដោយប្រើផ្ទាំងរូបភាពធំនៃកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4Cs) និងសៀវភៅណែនាំអំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋដោយមានការណែនាំបច្ចេកទេស ឬតម្រង់ទិសពីរបៀបនៃការផលិតព័ត៌មានការដាក់តាំងបង្ហាញការផ្សព្វផ្សាយ និងរបៀបនៃការប្រើប្រាស់ព័ត៌មានទាំងនេះក្នុងដំណើរការផ.អ.គ.ស.។

ឃ.សហការបណ្តុះបណ្តាលតម្រង់ទិសដល់មន្ត្រីបង្គោលរបស់អង្គការដៃគូអនុវត្ត (NGOs) ស្តីពីផែនការអនុវត្តការងារគណនេយ្យភាពសង្គមដើម្បីអោយមានភាពស្របគ្នាជាមួយនឹងវគ្គបណ្តុះបណ្តាលបន្តរបស់ផ្នែកតម្រូវការដល់ដៃគូតាមបណ្តាស្រុកគោលដៅ។

ង.ផ្តល់ថវិកាគាំទ្រអោយទាន់ពេលវេលាទៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅតំបន់គោលដៅដើម្បីអោយការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមស្របតាមផែនការ ក្រោមការទទួលខុសត្រូវរបស់រដ្ឋបាលទាំងនោះ។

ច. ត្រួតពិនិត្យការអនុវត្តជាប្រចាំនូវការបំពេញការងារ ការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាតិមន្ត្រីជំនាញផ្នែកសុខាភិបាល និងអប់រំដែលពាក់ពន្ធ័ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ និងដំណើរការដាក់ពិន្ទុដោយផ្នែកទាំងពីរ អង្គភាពផ្តល់សេវា និងប្រជាពលរដ្ឋ ក្នុងដំណើរការអនុវត្ត ផ.អ.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវពេញលេញ និងស្របតាមផែនការអនុវត្តការងារគណនេយ្យភាពសង្គម និងសៀវភៅ ណែនាំស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់។

ឆ. រៀបចំ និងចែករំលែកនូវរបាយការណ៍ ស្តីពីវឌ្ឍនៈភាពនៃការអនុវត្តជាទៀងទាត់ដូចដែលបានឯកភាពគ្នា តាមមាតិកានៃរបាយការណ៍ដែលមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធទី ២។

ជ.អនុវត្តប្រកបដោយសង្គតិភាពពីមួយឆ្នាំទៅមួយឆ្នាំតាមដែលអាចធ្វើបាននៅក្នុងតំបន់គោលដៅដើម្បីជៀសវាងការបញ្ឈប់ឬរំខានដល់ដំណើរការនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ។

## ប្រការ៤៖ ការទទួលខុសត្រូវរបស់អង្គការយែរអន្តរជាតិប្រចាំកម្ពុជា

អង្គការយែរអន្តរជាតិប្រចាំកម្ពុជា ព្រមព្រៀងដូចខាងក្រោម៖

ក.ផ្តល់ការណែនាំដល់បុគ្គលិកនិងអង្គការសង្គមស៊ីវិលដៃគូអនុវត្តរបស់ខ្លួនទាក់ទងនឹងខ្លឹមសារនៃអនុស្សារណៈនេះ។

ខ.ធានាថាការបណ្ដុះបណ្ដាលត្រូវបានផ្ដល់ដល់ដៃគូអង្គការសង្គមស៊ីវិលដែលជាដៃគូអនុវត្តរបស់ខ្លួន អំពីទស្សនៈទាន ឧបករណ៍នីតិវិធីដំណើរការគោលការណ៍អភិបាលកិច្ចល្អ ខ្សែគណនេយ្យភាព សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋក្នុងការអនុវត្តផ.អ.គ.ស។

គ.ផ្ដល់ថវិកាគាំទ្រអោយទាន់ពេលវេលាដល់អង្គការសង្គមស៊ីវិលដែលជាដៃគូរបស់ខ្លួនដើម្បីគាំទ្រការអនុវត្តសកម្មភាពផ្នែកតម្រូវការក្រោមការទទួលខុសត្រូវរបស់អង្គការដៃគូនោះ។

ឃ.ត្រួតពិនិត្យការអនុវត្តជាប្រចាំរបស់ខ្លួន ឬអង្គការសង្គមស៊ីវិលដែលជាដៃគូអនុវត្តរបស់ខ្លួន ដើម្បីធានាថាផ.អ.គ.ស ត្រូវបានអនុវត្តត្រឹមត្រូវពេញលេញដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមឯកសារផែនការអនុវត្តការងារគណនេយ្យភាពសង្គម និងសៀវភៅណែនាំស្ដីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាព សង្គមរបស់ផ្នែកតម្រូវការ។

ង.រៀបចំ និងចែករំលែកនូវរបាយការណ៍ស្ដីពី វឌ្ឍនៈភាពនៃការអនុវត្តជាទៀងទាត់ ដូចដែលបានឯកភាពគ្នាតាមមាតិកានៃរបាយការណ៍ដែលមានភ្ជាប់ជូនជូនក្នុងឧបសម្ព័ន្ធទី ២។

ច.អនុវត្តប្រកបដោយសង្គតិភាពពីមួយឆ្នាំទៅមួយឆ្នាំតាមដែលអាចធ្វើបាននៅក្នុងស្រុក/ឃុំ ដើម្បីជៀសវាង ការបញ្ឈប់ឬរំខានដល់ដំណើរការនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ។

## ប្រការ៥៖ ការចាត់ចែងសម្របសម្រួល

ក្នុងករណីចាំបាច់ ភាគីទាំងពីរអាចរៀបចំប្រជុំសម្របសម្រួលលើដំណើរការអនុវត្តគណនេយ្យភាពសង្គមជាប្រចាំ ក្នុងគោលបំណងដូចខាងក្រោម៖

- ពិនិត្យមើលអំពីភាពរីកចម្រើននៃការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គម
- កំណត់ពីបញ្ហា និងស្វែងរកដំណោះស្រាយប្រកបដោយការសហការគ្នា
- ពិភាក្សានិងព្រមព្រៀងលើចំណុចកែលម្អក្នុងដំណើរការអនុវត្តដែលបានលើកឡើង ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអនុវត្តនាពេលអនាគត
- ការងារផ្សេងៗទៀតទាក់ទងនឹងការអនុវត្តផែនការគណនេយ្យភាពសង្គមជាទូទៅ។

## ប្រការ៦៖ ការធ្វើវិសោធនកម្ម ឬការបញ្ចប់អនុស្សារណៈយោគយល់

អនុស្សារណៈយោគយល់នេះ អាចនឹងត្រូវបានធ្វើវិសោធនកម្មនៅពេលណាមួយក្នុងករណីដែលមានការព្រមព្រៀងពីភាគីទាំងពីរ។ ការបញ្ចប់អនុស្សារណៈនេះ នឹងតម្រូវអោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងតិច ៨ សប្ដាហ៍មុន និងមានការព្រមព្រៀងពីភាគីទាំងពីរទៅលើវិធានការសមស្របដើម្បីធានាឲ្យមានការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងតំបន់គោលដៅបន្ទាប់ពីការបញ្ចប់អនុស្សារណៈយោគយល់នេះ។ ៚

| | លេខាធិការដ្ឋានគ.ជ.អ.ប | អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា |
|---|---|---|
| ហត្ថលេខា៖ | | |
| ឈ្មោះ៖ | សក់ សេដ្ឋា | ចូអាន ហ្វែលលី |
| មុខងារ៖ | ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប | នាយិកាអង្គការឃែរអន្តរជាតិប្រចាំកម្ពុជា |
| កាលបរិច្ឆេទ៖ | ០៩ មិក ២០១៦ | ០៩ មិក ២០១៦ |

## ឧបសម្ព័ន្ធទី១÷

## ក. តំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៦ ដែលកំណត់ក្នុងអនុស្សារណៈរវាង លេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការឃែរអន្តរជាតិប្រចាំកម្ពុជា

| កូដ GIS | ឈ្មោះស្រុក | ចំនួនឃុំ | | ចំនួនសាលាបឋមសិក្សា | | ចំនួនមណ្ឌលសុខភាព | | អង្គការដៃគូមូលដ្ឋាន |
|---|---|---|---|---|---|---|---|---|
| | | ផ្នែកផ្តត់ផ្គង់ | ផ្នែកតម្រូវការ | ផ្នែកផ្តត់ផ្គង់ | ផ្នែកតម្រូវការ | ផ្នែកផ្តត់ផ្គង់ | ផ្នែកតម្រូវការ | |
| 16 | ខេត្តរតនៈគីរី | 12 | 8 | 56 | 32 | 3 | 2 | 4 |
| 1604 | កូនមុំ | 6 | 4 | 26 | 16 | 1 | 1 | 2LNGOs |
| 1605 | លំផាត់ | 6 | 4 | 30 | 16 | 2 | 1 | 2LNGOs |
| 11 | ខេត្តមណ្ឌលគីរី | 15 | 12 | 68 | 48 | 9 | 6 | 6 |
| 1101 | កែវសីមា | 5 | 4 | 27 | 16 | 3 | 2 | 2LNGOs |
| 1102 | កោះញែក | 6 | 4 | 25 | 16 | 3 | 2 | 2LNGOs |
| 1104 | ពេជ្រាដា | 4 | 4 | 16 | 16 | 3 | 2 | 2LNGOs |
| 09 | ខេត្តកោះកុង | 16 | 12 | 68 | 42 | 7 | 6 | 6 |
| 0901 | បុទុមសាគរ | 4 | 4 | 16 | 16 | 3 | 2 | 2LNGOs |
| 0906 | ស្រែ អំបិល | 6 | 4 | 39 | 16 | 2 | 2 | 2LNGOs |
| 0907 | ថ្មបាំង | 6 | 4 | 13 | 10 | 2 | 2 | 2LNGOs |
| 07 | ខេត្តកំពត | 29 | 8 | 94 | 32 | 16 | 8 | 2 |
| 0703 | ឈូក | 15 | 4 | 50 | 16 | 9 | 4 | 2LNGOs |
| 0706 | កំពង់ត្រាច | 14 | 4 | 44 | 16 | 7 | 4 | 2LNGOs |
| | សរុប | 72 | 40 | 286 | 154 | 35 | 22 | 18 |

២. ផែនការស្តីពីតំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៧ និង ២០១៨ ដែលកំណត់ក្នុងអនុស្សារណៈរវាង លេខាធិការដ្ឋាន.ប.អ.ជ.គ និងអង្គការឃែរអន្តរជាតិប្រចាំកម្ពុជា

តំបន់គោលដៅ ផ្នែកតម្រូវការនៃផែនការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម ឆ្នាំ ២០១៧ ដល់ ២០១៨

| កូដ GIS | ខេត្ត | ស្រុក | ២០១៧ ដល់ ២០១៨ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនស្រុក | ចំនួនឃុំ | | ចំនួនមណ្ឌលសុខភាព | | ចំនួនសាលារៀន | | ចំនួនអង្គការដៃគូអនុវត្ត |
| | | | | ចំនួនគ្រោង | ចំនួនអនុវត្ត | ចំនួនសរុប (*) | ចំនួនអនុវត្ត | ចំនួនសរុប | ចំនួនអនុវត្ត | |
| | ៤ | | ២៥ | ១៧៧ | ៥៧ | ៨៩ | ៣៧ | ៦៦១ | ២១២ | ២៧ |
| ៧ | កំពត | | | | | | | | | |
| ៧០១ | ១ | អង្គរជ័យ | ១ | ១១ | ២ | ៨ | ២ | ៤៣ | ៨ | ១ |
| ៧០២ | ២ | បន្ទាយមាស | ១ | ១៥ | ២ | ៩ | ២ | ៤៦ | ៨ | ១ |
| ៧០៣ | ៣ | ឈូក | ១ | ១៥ | ៤ | ១០ | ៤ | ៥០ | ១៦ | ២ |
| ៧០៤ | ៤ | ជុំគីរី | ១ | ៧ | ០ | ៧ | ០ | ២៨ | ០ | ០ |
| ៧០៥ | ៥ | ដងទង់ | ១ | ១០ | ២ | ៦ | ២ | ២៩ | ៨ | ១ |
| ៧០៦ | ៦ | កំពង់ត្រាច | ១ | ១៤ | ៤ | ៧ | ៤ | ៤៤ | ១៦ | ១ |
| ៧០៧ | ៧ | ទឹកឈូ | ១ | ១៦ | ០ | ១១ | ០ | ៥៥ | ០ | ០ |
| | សរុប | | ៧ | ៨៨ | ១៤ | ៥៨ | ១៤ | ២៩៥ | ៥៦ | ៦ |
| ៩ | កោះកុង | | | | | | | | | |
| ៩០១ | ១ | បុទុមសាគរ | ១ | ៤ | ៤ | ២ | ២ | ១៦ | ១៦ | ២ |
| ៩០២ | ២ | គីរីសាគរ | ១ | ៣ | ៣ | ១ | ១ | ១១ | ១២ | ១ |
| ៩០៣ | ៣ | កោះកុង | ១ | ៤ | ០ | ១ | ០ | ១១ | ០ | ០ |
| ៩០៥ | ៤ | មណ្ឌលសីមា | ១ | ៣ | ២ | ២ | ២ | ១៥ | ៨ | ១ |
| ៩០៦ | ៥ | ស្រែអំបិល | ១ | ៦ | ៤ | ២ | ២ | ៣៩ | ៨ | ២ |
| ៩០៧ | ៦ | ថ្មបាំង | ១ | ៦ | ៤ | ២ | ២ | ១៣ | ៨ | ២ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | | ៦ | ២៦ | ១៧ | ១០ | ៩ | ១០៥ | ៥២ | ៨ |
| ១១ | មណ្ឌលគីរី | | | | | | | | | |
| ១១០១ | ១ | កែវសីមា | ១ | ៥ | ៤ | ៣ | ៣ | ២៧ | ១៦ | ២ |
| ១១០២ | ២ | កោះញែក | ១ | ៦ | ៤ | ២ | ២ | ២៥ | ១៦ | ២ |
| ១១០៣ | ៣ | អូររាំង | ១ | ២ | 0 | ២ | 0 | ១០ | 0 | 0 |
| ១១០៤ | ៤ | ពេជ្រដា | ១ | ៤ | ២ | ៣ | ២ | ១៧ | ៨ | ១ |
| | សរុប | | ៤ | ១៧ | ១០ | ១០ | ៧ | ៧៩ | ៤០ | ៥ |
| ១៦ | រតនគីរី | | | | | | | | | |
| ១៦០១ | ១ | អណ្ដូងមាស | ១ | ៣ | ២ | ២ | ២ | ១៦ | ៨ | ១ |
| ១៦០៣ | ២ | បរកែវ | ១ | ៦ | ២ | ១ | ១ | ៣០ | ៨ | ១ |
| ១៦០៤ | ៣ | កូនមុំ | ១ | ៦ | ៤ | ១ | ១ | ២៦ | ១៦ | ២ |
| ១៦០៥ | ៤ | លំផាត់ | ១ | ៦ | ៤ | ១ | 1 | 28 | ១៦ | ២ |
| ១៦០៦ | ៥ | អូរ ជុំ | ១ | ៧ | 2 | 1 | 1 | 24 | ៨ | ១ |
| ១៦០៧ | ៦ | អូរយ៉ាដាវ | ១ | ៧ | 2 | 1 | 1 | 23 | ១ | ១ |
| ១៦០៨ | ៧ | តាវែង | ១ | ២ | 0 | 1 | 0 | 9 | 0 | 0 |
| ១៦០៩ | ៨ | វើនសៃ | ១ | ៩ | 0 | 3 | 0 | 26 | 0 | 0 |
| | សរុប | | ៨ | ៤៦ | ១៦ | 11 | 7 | 182 | ៦៤ | ៨ |

***បញ្ជាក់៖តារាងផែនការស្ដីពីតំបន់គោលដៅសម្រាប់អនុវត្តឆ្នាំ ២០១៧ និង ២០១៨ ខាងលើអាចនឹងមានការផ្លាស់ប្ដូរក្នុងករណីចាំបាច់ ដោយស្របតាមការពិភាក្សា និងឯកភាពរវាងភាគីទាំងពីរ***

តំបន់គោលដៅ ដែលនៅសល់គឺសំរាប់ត្រួតពិនិត្យ និងវាយតំលៃ។ អង្គការឃែរអន្តរជាតិប្រចាំកម្ពុជានឹងជ្រើសរើស៧អង្គការសង្គមស៊ីវិលផ្សេងទៀតសំរាប់ស្វែងយល់ពីសកម្មភាព ក៏ដូចជាការពង្រឹងសមត្ថភាព និងការសិក្សារៀនសូត្រ។

# ឧបសម្ព័ន្ធទី២៖ ទម្រង់មាតិកានៃរបាយការណ៍ស្តីពីការអនុវត្តការងារ

# គណនេយ្យភាពសង្គម

១. សេចក្តីផ្តើម

២. វឌ្ឍនះភាពនៃការអនុវត្ត

៣. បញ្ហាប្រឈម

៤ ស្ថានភាពហិរញ្ញវត្ថុ

៥. សេចក្តីសន្និដ្ឋាន